រក្សាសិទ្ធិ © ពត៌មាន :
© ២០០១ Project WorldReach © ២០០១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

029KH01A-01

ចូរស្វែងរកព្រះរាជ្យ
របស់ព្រះជាម្ចាស់ជាមុនសិន



កូនស្បៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២៩

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនក្រុមជំនុំ ឬ ក្រុមរបស់អ្នកឱ្យចេះស្វែងរកព្រះរាជ្យ
  របស់ព្រះជាម្ចាស់ និងសេចក្តីសុចរិតរបស់ព្រះអង្គ ជាមុន
  សិន (ម៉ាថាយ ៦:៣៣) ។

- អធិស្ឋាន និងរិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ ជា
  រៀងរាល់ថ្ងៃ ដើម្បីអោយដឹងពីព្រះហឫទ័យរបស់ព្រះគ្រីស្ត
  ដែលជាព្រះមហាក្សត្ររបស់យើងគ្រប់ៗគ្នា ។

- ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ដោយប្រតិបត្តិតាមព្រះ-
  គម្ពីរ ដើម្បីដោះស្រាយសេចក្តីត្រូវការខាងសម្ភារៈ និង
  ប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។

- ទុកចិត្តលើព្រះជាម្ចាស់ អោយព្រះអង្គផ្គត់ផ្គង់ការខ្វះខាត
  របស់ពួកយើង ដោយមិនពិបាកចិត្តខ្លាំងពេកអំពីសម្ភារៈ ។



© Project WorldReach © SEAN



☐ ខ្ជល់ខ្ជាយ និង ក្រៀមក្រំជាប់ជានិច្ច ។

មិនមែនយើងមិនត្រូវទូលសុំរបស់របរខាងសម្ភារៈពីព្រះ-ជាម្ចាស់ទេ ប៉ុន្តែ យើងត្រូវទូលសូមព្រះអង្គអំពីអ្វីៗខាងព្រលឹងវិញ្ញាណជាមុនសិន ។ បន្ទាប់មក ទើបយើងអាចទូលសុំព្រះអង្គឱ្យបំពេញការខ្វះខាតប្រចាំថ្ងៃរបស់យើង ។

២- នៅពេលដែលយើងមានការខ្វះខាត តើយើងត្រូវទៅរកអ្នកណាមុនគេ ?

☐ ទៅរកសាសនទូត ។

☐ ទៅរកអ្នកជិតខាងដែលជាអ្នកមាន ។

☐ ទៅរកក្រុមជំនុំ ។

☐ ទៅរកព្រះជាម្ចាស់ ។

៣- តើអ្នកទៅរកព្រះជាម្ចាស់ ទូលសូមឱ្យព្រះអង្គជួយបំពេញការខ្វះខាតរបស់អ្នកជាមុនដែរឬទេ ?

☐ ខ្ញុំទៅរកព្រះជាម្ចាស់ជាមុន ។

☐ អត់ទេ តែខ្ញុំនឹងចាប់ផ្តើម ។

© Project WorldReach © SEAN

ចុះអ្នកវិញ ?

គ្រីស្តជនជាច្រើនក្រខាងសម្ភារៈ ប៉ុន្តែ មានក្នុងព្រះគ្រីស្ត (១ ពេត្រុស ១:៣-៧) ។

សូមយើងកុំធ្លាក់ទឹកចិត្ត ដោយសារតែយើងក្រឡើយ (ភីលីព ៤:១១-១៤) ។

មិនត្រូវយកលេសថាក្រពេក មិនអាចឧបត្ថម្ភការងារថ្វាយព្រះ-គ្រីស្តនោះឡើយ (លូកា ២១:១-៤) ។

អ្នកដែលមានបំណងធ្វើដូចនេះ នឹងនៅតែក្រហូត ។ បើយើងមានចិត្តទូលាយ ព្រះជាម្ចាស់ក៏ទូលាយជាមួយយើងដែរ (លូកា ៦:៣៨) ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- មុននឹងទូលសូមអ្វីមួយពីព្រះជាម្ចាស់ តើយើងត្រូវធ្វើដូចម្តេច ?

- ☐ ស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងធ្វើតាមព្រះ-ហឫទ័យរបស់ព្រះអង្គ ។
- ☐ សុំអ្វីមួយពីមិត្តភក្តិយើងដែលជាអ្នកមាន ។



© Project WorldReach © SEAN

លោកគ្រូ ! ខ្ញុំញញឹមដូចម្តេចកើត បើខ្ញុំមិនអាចចិញ្ចឹមកូនខ្លួនឯងបានត្រឹមត្រូវផងនោះ ?



តើព្រះគម្ពីរចែងដូចម្តេច អំពីសេចក្តីត្រូវការខាងសំភារៈរបស់ប្អូននោះ ?

ត្រូវហើយ ខ្ញុំបានសាកល្បងនៅក្នុងគ្រួសារខ្ញុំហើយ ។ ឥឡូវនេះ យើងចេះទុកចិត្តលើព្រះជាម្ចាស់អោយជួយដោះស្រាយសេចក្តីខ្វះខាតរបស់យើង ។ ព្រះអង្គតែងតែប្រទានពរអោយពួកអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ។ ខ្ញុំក៏នឹងជាក់ជង្វាយដប់ភាគរយដែរ ។



© Project WorldReach © SEAN

ក្រែងព្រះគម្ពីរនិយាយតែពីសេចក្តីត្រូវការរបស់យើងខាងព្រលឹងវិញ្ញាណទេអ្ហឺ ?



ផ្ទុយទៅវិញទេប្អូន ព្រះជាម្ចាស់យកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការគ្រប់យ៉ាងរបស់យើង ដូចដែលព្រះយេស៊ូមានព្រះបន្ទូលក្នុងលូកា ១២:២២-៣៤ ណា+ ។

ព្រះជាម្ចាស់រក្សាពាក្យសន្យារបស់ព្រះអង្គណាស់ ។ ចូរស្វែងរកព្រះរាជ្យរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គនឹងប្រទានអ្វីៗដែលយើងត្រូវការមកថែមទៀត ។




អញ្ចឹង ! ប្រហែលសាសនទូតដែលជាអ្នកមាន អាច
ជួយខ្ញុំបាន ។ រួច...


ប៊ុណ្ណាប្រាប់យើងថា ព្រះជាម្ចាស់បណ្តាលចិត្តគាត់ឲ្យ
យកម្ហូបអាហារនោះមកអោយយើង ។ ដូច្នេះ គាត់
មានបំណងចង់ជួយយើង ។ ប៊ុណ្ណាចាប់ផ្តើមជាក់
ដង្វាយដប់ភាគរយ មួយឆ្នាំមកហើយ ។ ឥឡូវនេះ
កិច្ចការគ្រប់យ៉ាងដែលគាត់បានធ្វើ សុទ្ធតែចំរើនទាំង
អស់ !

ទេ កុំទៅរំខានសាសនទូតអី ! ទុកឲ្យគាត់ជួយបង្ហាត់បង្រៀនគ្រូគង្វាលនៅក្នុងក្រុមជំនុំថ្មីៗវិញចុះ ! មនុស្សដែលកំពុងបាត់បង់ ហើយកំពុងដើរទៅរកស្ថាននរក ត្រូវការសាសនទូតខ្លាំងជាងប្អូនណា៎តារា ។ នែ៎ ! សូមមើលលូកា ១២:២២-៣៤ជាមួយគ្នាវិញណា៎ ។



ទូលសូមព្រះវិញ្ញាណដ៏វិសុទ្ធអោយបំភ្លឺគំនិតប្រាជ្ញា និង ចិត្តគំនិតអ្នក ដោយសារការសិក្សានេះ ហើយរៀបចំបង្រៀនសមាជិករបស់អ្នក អោយចេះស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់សិន មុននឹងស្វែងរកអ្វីៗគ្រប់យ៉ាងផ្សេងទៀត ។ បន្ទាប់មក អានលូកា ១២:២២-៣៤ ដើម្បីអានព្រះបន្ទូល ដែលព្រះជាម្ចាស់ទុកសំរាប់ពួកអ្នកដែលពិបាកចិត្តខ្លាំង ។

បាទ ! ឥឡូវនេះ ខ្ញុំឈប់គិតច្រើនអំពីការខ្វះខាតហើយ ។ ព្រះជាម្ចាស់បានប្រទានអោយខ្ញុំមានសេចក្តីសុខសាន្ត ។ ពីថ្ងៃមុន យើងគ្មានអ្វីហូបទាល់តែសោះ ។ តែយើងនាំគ្នាអធិស្ឋានថ្វាយការខ្វះខាតនេះទៅក្នុងព្រះហស្តព្រះជាម្ចាស់ ។ នៅថ្ងៃនោះ ល្ងាចបន្តិច ស្រាប់តែមានអ្នកជិតខាងយើងម្នាក់ឈ្មោះប៊ុណ្ណាមកផ្ទះយើង ហើយយកម្ហូបអាហារមកអោយយើង !



តើសត្វស្លាបដែលខ្ទល់ខ្ទាយអំពីអ្វីដែលវាត្រូវស៊ី នៅថ្ងៃស្អែកដែរឬទេ ? _____

ហេតុអ្វីបានជាសត្វស្លាបមិនខ្ទល់ខ្ទាយ ? (ខ ២៤) សូមសរសេរចំលើយរបស់អ្នក :

_____

_____

តើអ្នកណាដែលចេះតែខ្ទល់ខ្ទាយតែពីសម្ភារៈ ? (ខ ៣០)

_____

តើអ្វីដែលសំខាន់បំផុតសំរាប់យើងរាល់គ្នាដែលជាអ្នកជឿ ? (ខ ៣១)

_____

តើអ្នកមានបំណងចង់បានអ្វីខ្លាំងជាងគេ ?

☐ ទ្រព្យសម្បត្តិ ។

☐ ចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយនិងធ្វើតាមព្រះហឫទ័យព្រះអង្គ ។

ប្អូនរីកចំរើនឡើងក្នុងព្រះគ្រីស្តហើយ ។ ប្អូនកំពុងក្លាយជាគ្រីស្តជនចាស់ទុំខាងព្រលឹងវិញ្ញាណហើយ ។ ការដែលប្អូនអធិស្ឋាន និងអានព្រះគម្ពីរនៅពេលព្រឹក ពិតជាអំណរមួយមែនទេ ? តើប្អូននៅតែពិបាកចិត្តដោយសារប្អូនខ្វះខាតទៀតទេ ?



© Project WorldReach © SEAN

ប្អូនតារា ! ព្រះវិញ្ញាណដ៏វិសុទ្ធពិតជាកំពុងធ្វើការក្នុងចិត្តប្អូនមែន ។ ឥឡូវនេះ ប្អូនឈប់ពិបាកចិត្តអំពីរឿងរបស់ប្អូនដូចពីមុនទៀតហើយ ។



បើយើងចង់បានខ្លាំងដូចពួកអ្នកមាន តើនឹងមានរឿងអ្វីកើតឡើង ?

☐ **យើងនឹងឈឺខាងព្រលឹងវិញ្ញាណ ។**

☐ **យើងនឹងបានដូចចិត្តប្រាថ្នារបស់យើង ។**

នៅក្នុង ១ ២២ និង ២៣ ព្រះយេស៊ូមានបន្ទូលថា “កុំអោយខ្វល់ខ្វាយអំពីម្ហូបអាហារ សំរាប់ចិញ្ចឹមជីវិត ឬអំពីសម្លៀកបំពាក់សំរាប់បិទបាំងរូបកាយឡើយ ដ្បិតជីវិតមានតម្លៃលើសម្ហូបអាហារ ហើយរូបកាយមានតម្លៃលើសសម្លៀកបំពាក់ទៅទៀត” ។




លោកគ្រូ ជីវិតមានតម្លៃលើសម្លូបអាហារមែន ។ ប៉ុន្តែ យើងក៏ត្រូវហូបចុក និងមានរបស់របរផ្សេងៗ សំរាប់ជីវិតដែរ ។ លោកគ្រូមើលបុរសម្នាក់នោះចុះ ! លោកគ្រូឃើញគេរស់របៀបណាទេ ដោយសារគេជាអ្នកមានណា៎ ។


គឺរាល់ព្រឹក ខ្ញុំទូលសូមអោយព្រះជាម្ចាស់បង្ហាញខ្ញុំឲ្យដឹងពីព្រះហឫទ័យព្រះអង្គសំរាប់ថ្ងៃនោះ ។ មុននឹងចេញទៅធ្វើការ ខ្ញុំអានព្រះគម្ពីរ ។ រួចខ្ញុំគិតពីសេចក្តីដែលខ្ញុំបានអាននោះ ពេញមួយថ្ងៃ ។

ព្រះជាម្ចាស់កំពុងប្រទានពរឱ្យពួកខ្ញុំ ។ ខ្ញុំបានពន្យល់
វគ្គព្រះគម្ពីរក្នុងលូកា ១២:២២-៣៤ ប្រាប់ប្រពន្ធខ្ញុំ
ហើយយើងបានអធិស្ឋានទាំងអស់គ្នា ។ ឥឡូវនេះ
យើងកំពុងស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និង
សេចក្តីសុចរិតរបស់ព្រះអង្គមុនអ្វីៗទាំងអស់ ។ យើង
បានកែតម្រង់ខ្លួនតាមការដាស់តឿនរបស់លោកគ្រូ
ហើយ ។



ចុះប្អូនទាំងពីរនាក់ធ្វើអ្វី ដើម្បីស្វែងរកព្រះរាជ្យរបស់
ព្រះជាម្ចាស់មុនអ្វីៗទាំងអស់ ?

កុំគិតអញ្ចឹងប្អូន ។ បើប្អូនចេះតែគិតពីមនុស្សដែលមាន
ជាងប្អូន នោះនាំឱ្យប្អូនច្រណែននឹងគេតែប៉ុណ្ណោះ ។
ការច្រណែនមានឥទ្ធិពលអាក្រក់ ធ្វើឱ្យវិញ្ញាណរបស់ប្អូន
ខ្ចេចខ្ចាំ ។ សូមប្អូនសំឡឹងទៅព្រះជាម្ចាស់ជាមុនសិន ។
ព្រះអង្គដឹងថា យើងត្រូវការហូបចុក ។ ព្រះអង្គមាន
បន្ទូលនៅក្នុងលូកា ១២:២៩ ថា៖ “ដូច្នេះ ចូរអ្នក
រាល់គ្នាកុំគិតតែពីស្វែងរកគ្រឿងបរិភោគនោះឡើយ” ។



ប៉ុន្តែ បើមិនខ្វល់ខ្វាយពីរឿងនេះ តើឲ្យនរណាខ្វល់ខ្វាយវិញ ? បើពួកអ្នកមាន គេមិនចាប់អារម្មណ៍នឹងយើងសោះនោះ !



ប៉ុន្តែ យើងត្រូវទុកចិត្តលើព្រះជាម្ចាស់ ។ នៅក្នុង ១ បន្ទាប់ ព្រះយេស៊ូមានបន្ទូលថា៖ “ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះ ដែលខំស្វះស្វែងរករបស់ទាំងនោះ ។ រីឯអ្នករាល់គ្នាវិញ ព្រះបិតារបស់អ្នករាល់គ្នា ទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ” ។

តារាបន្តអធិស្ឋាន និង រិះគិតពិចារណាពីព្រះបន្ទូលរបស់ព្រះ-ជាម្ចាស់ ជារៀងរាល់ថៃ ។ បន្ទាប់មក...

លោកគ្រូ ! ខ្ញុំសប្បាយចិត្តណាស់ ដែលលោកគ្រូមកលេងពួកខ្ញុំម្តងទៀត ! ពួកខ្ញុំមានរឿងខ្លះចង់ជំរាបលោកគ្រូ ។



ប្អូនតារា ! ប្អូនរីករាយវិញហើយ ! មានការអ្វីហ្នឹង ?



គ្រូគង្វាលនៅតែព្យាយាមយកព្រះគម្ពីរមកដោះស្រាយបញ្ហារបស់តារា ។ គាត់ជួយជនអោយទន្ទេញខគម្ពីរមួយ :

ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្តីសុចរិតរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត ។

(ម៉ាថាយ ៦:៣៣)



ប្អូនបានសង្គ្រោះហើយ តែប្អូននៅខ្វះសេចក្តីសុខសាន្ត។ ប្អូនត្រូវតែតម្រង់គំនិតប្រាជ្ញារបស់ប្អូន ។ សូមប្អូនសិក្សាព្រះគម្ពីរ និងអធិស្ឋានរាល់ថ្ងៃទៅ ។ សូមប្អូនស្វែងរកព្រះហឫទ័យព្រះជាម្ចាស់សំរាប់ប្អូន និងស្តាប់តាមព្រះអង្គក្នុងគ្រប់កិច្ចការចុះ ។ ពេលនោះប្អូននឹងបានសុខសាន្តហើយ ។



នៅថ្ងៃបន្ទាប់....

(សំលេងខ្សឹប !) មើល៍ហ្ន៎ ! នោះអ្នកមានកំពុងដើរ ។ ទៅសុំអ្វីពីគាត់ ដោយប្រាប់គាត់ថាឯងក្រណាស់ទៅ ។







© Project WorldReach © SEAN

ព្រះបិតាអើយ ទូលបង្គំមិនបានយល់ពីសេចក្តីទាំងអស់នេះទេ ។ ប៉ុន្តែ ដោយសារសេចក្តីទាំងនេះមានចែងក្នុងព្រះគម្ពីរ នោះមានន័យថា សេចក្តីទាំងនេះសុទ្ធតែជាការពិត ។ ខ្ញុំនឹងស្វែងរកព្រះរាជ្យរបស់ព្រះអង្គជាមុនសិន ហើយខ្ញុំឈប់ព្រួយបារម្ភអំពីអ្វីៗទាំងអស់នេះ ។



ល្អណាស់ ចាប់ពីពេលនេះទៅ សូមប្អូនគិតតែអំពីកិច្ចការរបស់ព្រះជាម្ចាស់ នោះប្អូននឹងមានចិត្តស្រឡាញ់ពិតចំពោះព្រះជាម្ចាស់ និងចំពោះមនុស្សឯទៀត ។ សូមប្អូនឈប់ព្រួយចិត្តទៅ ព្រះជាម្ចាស់នឹងផ្គត់ផ្គង់អ្វីៗគ្រប់យ៉ាងដែលប្អូនពិតជាត្រូវការដល់ប្អូន ដោយសារប្អូនមានសេចក្តីស្រឡាញ់ និងមានជំនឿ ។ ព្រះអង្គនឹងជួយប្អូនអោយអាចកែតម្រង់ខ្លួនបាន ។ សូមប្អូនចាំថា ត្រូវអធិស្ឋាន និងរិះគិតពិចារណាពីព្រះបន្ទូលជារៀងរាល់ថ្ងៃ ។ ប៉ុន្តែ សូមចាំទៀតថា អារក្សនឹងខិតខំធ្វើឲ្យប្អូនភ្លេចសេចក្តីពិតដែលប្អូនទទួលស្គាល់នៅថ្ងៃនេះ ។ ដូច្នេះ យើងនឹងអធិស្ឋានពេលនេះ ដើម្បីទូលសូមអោយព្រះជាម្ចាស់ជួយប្អូន ។

